**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 14-Sep-2011, 14:31
CMS/CFO: Kauv Keoratanak

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីការពារក្តីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៤ខែ កញ្ញា ឆ្នាំ ២០១១

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះ

អាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## សំណើរបស់លោក អៀង សារី សុំពិនិត្យមើលឯកសារសម្ងាត់បំផុតនៅក្នុងសំណុំរឿង

---

**<u>សហមេធាវីការពារក្តី:</u>**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

**<u>ដាក់ជូន ៖</u>**

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម **និល ណុន**

ចៅក្រម **យូ អុត្តរា**

ចៅក្រម **យ៉ា សុខន**

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

ចៅក្រមបម្រុង **យូរ ឧត្តរ៉ា**

ចៅក្រមបម្រុង Claudia FENZ

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ក្រុមមេធាវីការពារក្ដីទាំងអស់**

**ដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់**

អនុលោមតាមវិធាន ២១(១) និងវិធាន ៨៦ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក (“វិធានផ្ទៃក្នុង”) ព្រមទាំងមាត្រា ២(ឃ)(iii) និងមាត្រា ៦ នៃសេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានដែលទាក់ទងសំណុំរឿង (“សេចក្តីណែនាំអនុវត្ត”) លោក អៀង សារី សូមស្នើ តាមរយៈសហមេធាវីការពារក្តី (“ក្រុមមេធាវីការពារក្តី”) ឲ្យអង្គជំនុំជម្រះសាលាដំបូងអនុញ្ញាតឲ្យក្រុមមេធាវីការពារក្តី មានលទ្ធភាពពិនិត្យមើលគ្រប់ឯកសារសម្ងាត់បំផុតទាំងអស់នៅក្នុងសំណុំរឿង។ ជាជម្រើសម្យ៉ាងទៀត ក្រុមមេធាវីការពារក្តី ស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូង ពិនិត្យ *ជាអសាធារណៈ* លើគ្រប់ឯកសារសម្ងាត់បំផុតទាំងអស់នៅក្នុងសំណុំរឿង ដើម្បីកំណត់ ថាតើឯកសារណាខ្លះ ប្រសិនបើមាន គួរលាតត្រដាងជូនក្រុមមេធាវីការពារក្តី ដោយមិនគិត ថាតើឯកសារទាំងនោះអាចនឹងត្រូវបង្ហាញនៅក្នុងពេលជំនុំជម្រះ ឬក៏មិនបង្ហាញនោះឡើយ។ សំណើសុំនេះត្រូវធ្វើឡើងជាចាំបាច់ ដោយហេតុថា នៅក្នុងសំណុំរឿងមានឯកសារសម្ងាត់បំផុតជាង ៥០០០ ឯកសារ ដែលក្រុមមេធាវីការពារក្តី ក្នុងពេលបច្ចុប្បន្ន មិនមានលទ្ធភាពពិនិត្យមើល ឬ ក៏មិនដឹងថាមានចំណងជើងយ៉ាងណាផង។ ករណីនេះគឺជាការរំលោភលើសិទ្ធិ ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់លោក អៀង សារី រួមទាំង ក) សិទ្ធិរបស់លោកក្នុងការពិនិត្យលើភស្តុតាង និងសាក្សី ដាក់បន្ទុកមកលើខ្លួន ខ) សិទ្ធិរបស់លោកទទួលបានសម្ភារៈគ្រប់គ្រាន់សម្រាប់ការការពារខ្លួន គ) គោលការណ៍សមភាពរវាងគូភាគីក្នុងការតទល់ក្តី។ ការលាតត្រដាងត្រឹមតែចំណងជើងទូទៅនៃឯកសារសម្ងាត់បំផុតទាំងនោះ មិនគ្រប់គ្រាន់ក្នុងការទប់ស្កាត់ការប៉ះពាល់លើសិទ្ធិក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់លោក អៀង សារី ឡើយ។

## I. **សាវតារ**

១. មានឯកសារសម្ងាត់បំផុតជាង ៥០០០ ឯកសារ នៅក្នុងសំណុំរឿង ដែលក្រុមមេធាវីការពារក្តីមិនមានលទ្ធភាពពិនិត្យមើល ឬមិនដឹងទាំងឈ្មោះចំណងជើងឯកសារនោះទេ[១]។ បញ្ជីសារពើភណ្ឌសំណុំរឿង រួមមានព័ត៌មានដ៏តិចតួចបំផុត ស្តីពីខ្លឹមសារនៃឯកសារ ដោយគ្រាន់តែបញ្ជាក់ថា ឧទាហរណ៍ ឯកសារនេះ ជា “ពាក្យសុំរបស់ជនរងគ្រោះ” “របាយការណ៍” ឬ “លិខិត” តែប៉ុណ្ណោះ[២]។

---

[១] សូមមើល ឧបសម្ព័ន្ធសម្រាប់បញ្ជីឯកសារ “សម្ងាត់បំផុត” នៅក្នុងសំណុំរឿង ០០២។

[២] ដូចខាងលើ។

២. ក.ស.ព បានដាក់ឯកសារទាំងនេះជាឯកសារសម្ងាត់បំផុត ដូចជា ក. អ្នកជំនាញស្របតាមវិធាន៨០ នៃវិធានផ្ទៃក្នុង បញ្ជីឈ្មោះអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី រួមទាំងឧបសម្ព័ន្ធសម្ងាត់ ទី១ ទី២ ទី៣ ទី៣ក ទី៤ និងទី៥[៣] ខ. បញ្ជីឯកសារសម្រាប់សវនាការ ស្របតាមវិធាន ៨០(៣) នៃវិធានផ្ទៃក្នុង[៤] និង គ. បញ្ជីឯកសារលើប្រធានបទបួនដំបូងសម្រាប់ការជំនុំជម្រះក្តី[៥]។ ក្រុមមេធាវីការពារក្តីមិនមានលទ្ធភាពពិនិត្យមើលឯកសារសម្ងាត់បំផុតទាំងនេះបានទេ ហើយក្រុមមេធាវីការពារក្តីក៏ពុំមានលទ្ធភាពដឹងចំណងជើងបានពេញលេញផងដែរ លើកលែងតែចំណងជើងទូទៅ ដែលបានផ្តល់ជូននៅក្នុងបញ្ជីសារពើភណ្ឌសំណុំរឿងតែប៉ុណ្ណោះ។

II. **ទន្ទឹករណ៍**

**ក. សិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់លោក អៀង សារី ត្រូវបានរំលោភ ប្រសិនបើលោកមិនទទួលបានការអនុញ្ញាតឲ្យពិនិត្យមើលឯកសារ "សម្ងាត់បំផុត" នៅក្នុងសំណុំរឿង**

៣. លោក អៀង សារី មានសិទ្ធិជាសារវ័ន្ត ទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌[៦]។ សិទ្ធិនេះរួមមានសិទ្ធិពិនិត្យភស្តុតាង និងសាក្សី ដែលដាក់បន្ទុកមកលើខ្លួន[៧] សិទ្ធិមានសម្ភារៈគ្រប់គ្រាន់សម្រាប់ការពារខ្លួន[៨] និងសិទ្ធិសមភាពនៃការតទល់ក្តីជាមួយនឹង ក.ស.ព[៩]។ ដើម្បីគោរពទៅតាមកាតព្វកិច្ច

---

[៣] បញ្ជីឈ្មោះអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី របស់សហព្រះរាជអាជ្ញា រួមទាំងឧបសម្ព័ន្ធសម្ងាត់ទី១ ទី២ ទី៣ ទី៣ក ទី៤ និង ទី៥ ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១១ E9/4។ ឧទាហរណ៍ នៅក្នុងឧបសម្ព័ន្ធ ៣ ក.ស.ព យោងទៅរកឯកសារលេខ **D230/1.1.874a**។

[៤] បញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា សម្រាប់សវនាការ ស្របតាមវិធាន ៨០(៣) ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១១ E9/31។ ឧទាហរណ៍ នៅក្នុងបញ្ជីនេះ ក.ស.ព យោងទៅរកឯកសារលេខ **D230/1/1/360a**។

[៥] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូង ស្នើសុំឯកសារដែលទាក់ទិននឹងដំណាក់កាលដំបូងនៃការជំនុំជម្រះលើអង្គសេចក្តី ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ E109/4។ នៅក្នុងបញ្ជីឯកសារនេះ ក.ស.ព យោងទៅរកឯកសារលេខ **D230/2/2.1.241a**។

[៦] សូមមើល ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៣៣។ កិច្ចព្រមព្រៀង មាត្រា ១២(២)។

[៧] សូមមើល ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៣៥ ថ្មី។ កិច្ចព្រមព្រៀង មាត្រា ១៣(១)។ វិធាន ៨៦ នៃវិធានផ្ទៃក្នុង។ សូមមើលផងដែរ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("កតិកាសញ្ញាអន្តរជាតិ") មាត្រា ១៤(៣)។

[៨] មាត្រា ៣៥ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចែងតម្រូវថា លោក អៀង សារី ត្រូវ "មានពេលវេលា និងលក្ខណៈគ្រប់គ្រាន់ដើម្បីរៀបចំការពារខ្លួន...."។ មាត្រា ១៤(៣)(ខ)នៃកតិកាសញ្ញាអន្តរជាតិចែងថា៖ "ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពី

របស់ខ្លួន ដូចមានចែងនៅក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងកិច្ចព្រមព្រៀង អង្គជំនុំជម្រះសាលាដំបូងត្រូវធ្វើយ៉ាងណាឲ្យការជំនុំជម្រះក្តីមានភាពយុត្តិធម៌។ សិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់លោក អៀង សារី ត្រូវបានរំលោភ ប្រសិនបើលោកមិនទទួលបានការអនុញ្ញាតឲ្យពិនិត្យមើលឯកសារសម្ងាត់បំផុតនៅក្នុងសំណុំរឿងនោះទេ។

៤. មាត្រា ២(ឃ)(iii) នៃសេចក្តីណែនាំអនុវត្ត កំណត់ "សម្ងាត់បំផុត" ថាជា "បើកចំហជូនចំពោះតែចៅក្រម បុគ្គលផ្សេងទៀត <u>ដែលរួមមានបុគ្គលិកតុលាការដែលត្រូវការពិនិត្យមើលឯកសារ ដើម្បីបំពេញភារកិច្ចរបស់ខ្លួន</u> ប៉ុន្តែសិទ្ធិមើលឯកសារ ត្រូវទទួលបានសេចក្តីសម្រេចពីតុលាការជាមុន"[១០]។ ដើម្បីបំពេញកាតព្វកិច្ចរបស់ខ្លួនឲ្យបានខ្ជាប់ខ្ជួននោះ ក្រុមមេធាវីការពារក្តីទាមទារឲ្យខ្លួនអាចមានលទ្ធភាពពិនិត្យមើលគ្រប់ឯកសារសម្ងាត់បំផុត<u>ទាំងអស់</u>នៅក្នុងសំណុំរឿង[១១]។ ការ

---

បទព្រហ្មទណ្ឌណាមួយ ប្រឆាំងមកលើខ្លួន ជនគ្រប់រូប មានសិទ្ធិទទួលបានការធានាជាអប្បបរមា ដោយស្មើភាពគ្នាយ៉ាងពេញលេញ ដូចខាងក្រោម៖... ត្រូវមានពេលវេលា និងសម្ភារៈរូបវ័ន្តគ្រប់គ្រាន់ សម្រាប់រៀបចំការពារខ្លួន"។

[៩] សមភាពរវាងគូភាគីក្តីមានន័យថា "ក្រុមមេធាវីការពារក្តី និងអយ្យការ ត្រូវមានសមភាពនីតិវិធី ដើម្បីធានាថា កិច្ចដំណើរការនីតិវិធី ដំណើរការប្រព្រឹត្តទៅដោយយុត្តិធម៌"។ រឿងក្តី កាំង ហ្គេកអ៊ាវ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ សេចក្តីសម្រេចលើសំណើរបស់ អៀង សារី សុំដាក់អំណះអំណាងឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាស្នើសុំឲ្យអនុវត្តសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ៣ ខែ កក្កដា ឆ្នាំ ២០០៩ ឯកសារលេខ D288/6.90 កថាខណ្ឌ ៥។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់នៅក្នុងសំណុំរឿង ០០១ ថា "លក្ខណៈជាមូលដ្ឋាននៃគោលការណ៍នេះ ត្រូវបានទទួលស្គាល់នៅក្នុងវិធានផ្ទៃក្នុង ...."ដូចខាងលើ។

[១០] គូសបញ្ជាក់បន្ថែម។ សូមមើលផងដែរ មាត្រា ៦ នៃសេចក្តីណែនាំអនុវត្ត៖ "ជាគោលការណ៍ ឯកសារ និងព័ត៌មាន ក្នុងចំណាត់ថ្នាក់ដូចខាងក្រោម ជាឯកសារ និងព័ត៌មានសម្ងាត់បំផុត លើកលែងតែមានចំណាត់ថ្នាក់ផ្សេងពីនេះ ដោយសេចក្តីសម្រេចរបស់តុលាការ៖ ក. សំណើសុំវិធានការការពារ និងឯកសារពាក់ព័ន្ធ (ដែលរួមមានការវាយតម្លៃអំពីហានិភ័យរបស់អង្គភាពគាំពារសាក្សី និងអ្នកជំនាញ)។ ខ. ឯកសារ និងព័ត៌មាន ដែលទាក់ទងនឹងវិធានការការពារ។ និង គ. ព័ត៌មានដែលទាក់ទងទៅនឹងសុខភាពរបស់ជន ជនត្រូវចោទ និងជនជាប់ចោទ"។

[១១] សូមមើល សេចក្តីសម្រេចលើបណ្តឹងរបស់លោក អៀង សារី ដែលប្តឹងជិតចិត្ត ចំពោះលោកចៅក្រម និល ណុន និងសំណើពាក់ព័ន្ធផ្សេងៗ ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១១ E5/3 កថាខណ្ឌ ២ ដែលអង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់នូវកាតព្វកិច្ចនៃការយកចិត្តទុកដាក់ឲ្យបានខ្ជាប់ខ្ជួនរបស់ភាគី។ វចនានុក្រម Black's Law កំណត់និយមន័យនៃពាក្យការយកចិត្តទុកដាក់ឲ្យបានខ្ជាប់ខ្ជួនថាជា "ការយកចិត្តដ៏សមហេតុផល ដែលរំពឹងទុកពី និងដែលអនុវត្តជាទូទៅដោយបុគ្គលណាម្នាក់ ដែលមានបំណងបំពេញទៅតាមលក្ខខណ្ឌច្បាប់ ឬ ដែលមានបំណងបំពេញកាតព្វកិច្ចណាមួយ" វចនានុក្រម BLACK'S LAW 468 (7th ed. 1999)។ សូមមើលផងដែរ *Prosecutor* ទល់នឹង *Delalić* និងជនដទៃទៀត IT-96-21-A សាលដីកា ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ៦៣១ ដែលអង្គជំនុំជម្រះតុលាការកំពូលនៃសាលាក្តី ICTY បានសម្រេចនៅក្នុងរឿងក្តី *Delalić* ថា

ផ្តល់ការអនុញ្ញាតឲ្យមានលទ្ធភាពពិនិត្យមើលសំណុំរឿងទាំងអស់ នឹងធានានូវការគោរពសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់លោក អៀង សារី។

**១. សិទ្ធិរបស់លោក អៀង សារី ក្នុងការពិនិត្យភស្តុតាង និងសាក្សី ដាក់បន្ទុកមកលើខ្លួន និងសិទ្ធិទទួលបានសម្ភារៈគ្រប់គ្រាន់សម្រាប់ការការពារ ខ្លួន ត្រូវបានរំលោភ នៅពេលលោកមិនបានទទួលការអនុញ្ញាតឲ្យពិនិត្យមើលឯកសារសម្ងាត់បំផុត**

៩. លោក អៀង សារី ត្រូវតែមានលទ្ធភាពពិនិត្យមើលគ្រប់ឯកសារសម្ងាត់បំផុតទាំងអស់នៅក្នុងសំណុំរឿង ដើម្បីជាការគោរពសិទ្ធិពិនិត្យភស្តុតាង និងសាក្សី ដែលដាក់បន្ទុកមកលើខ្លួន[១២]។ ដូចគណៈកម្មាធិការសិទ្ធិមនុស្ស ("គ.ស.ម") បានកត់សម្គាល់ឃើញថា ការការពារនេះ "មានសារៈសំខាន់នៅក្នុងការធានានូវសិទ្ធិការពារខ្លួនរបស់ជនជាប់ចោទ និងមេធាវីរបស់ខ្លួន និងធានាឲ្យជនជាប់ចោទ ទទួលបានអំណាចផ្លូវច្បាប់ស្មើគ្នា...នៅក្នុងការដេញដោលសាក្សីរបស់ខ្លួន និងសាក្សី

---

"ការខកខានរបស់មេធាវីការពារក្តី នៅក្នុងការជំទាស់ ជាទូទៅ នឹងបង្ហាញថា មេធាវីការពារក្តីរូបនោះមានការយល់ឃើញនៅពេលនោះថា បញ្ហាទាំងឡាយ ដែលចៅក្រមមិនបានយកចិត្តទុកដាក់ គឺមិនមានសារៈសំខាន់ចំពោះរឿងក្តីរបស់ខ្លួន ដែលកិច្ចដំណើរការនីតិវិធី មិនអាចបន្តទៅមុខបានទេ ប្រសិនបើមិនមានការយកចិត្តទុកដាក់លើបញ្ហាទាំងនោះ"។ អង្គជំនុំជម្រះតុលាការកំពូលនៃសាលាក្តី ICTY បានលើកឡើងនៅក្នុងរឿងក្តី *Tadić* ថា ការផ្តល់សិទ្ធិមួយចំនួនដល់ជនជាប់ចោទឲ្យស្របតាមលក្ខន្តិកៈនៃសាលាក្តី ICTY គឺមានគោលបំណងឲ្យ "ជនជាប់ចោទ អនុវត្តការយកចិត្តទុកដាក់របស់ខ្លួនឲ្យបានខ្ជាប់ខ្ជួន នៅក្នុងការប្រើប្រាស់សិទ្ធិទាំងនោះ"។ ចៅក្រម RICHARD MAY និងចៅក្រម MARIEKE WIERDA, INTERNATIONAL CRIMINAL EVIDENCE 306 (Transnational Publishers Inc., 2002) បានពិភាក្សាលើករណី រដ្ឋអាជ្ញា ទល់នឹង *Tadić* IT-94-1-A សាលដីកាលើសំណើសុំរបស់ម្ចាស់បណ្តឹងសាទុក្ខ ស្នើសុំពន្យាររយៈពេលកំណត់ និងស្នើសុំឲ្យទទួលយកភស្តុតាងបន្ថែម ចុះថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩៨។ ដូចអ្នកស្រាវជ្រាវមួយរូបបានលើកឡើង "ពាក់ព័ន្ធនឹងរយៈពេល និងសម្ភារៈ ក្រុមមេធាវីការពារក្តីត្រូវបានគេរំពឹងទុកឲ្យមានការយកចិត្តទុកដាក់មួយកម្រិតជាក់លាក់ ហើយ ជាការពិតទៅ ការយកចិត្តទុកដាក់មួយកម្រិតជាក់លាក់នេះ គឺជាលក្ខខណ្ឌតម្រូវមួយ។ <u>ក្រុមមេធាវីការពារក្តីអាចត្រឹមតែតវ៉ាអំពីការរំលោភសិទ្ធិរបស់ខ្លួនបាន ក្នុងករណីខ្លួនបានបំពេញកាតព្វកិច្ចអ្វីៗទៅតាមច្បាប់ជាតិដើម្បីទទួលបាន</u> <u>(ការពន្យាររយៈពេល) ឬ សម្ភារៈ</u>"។ STEFAN TRECHSEL, HUMAN RIGHTS IN CRIMINAL PROCEEDINGS 214 (Oxford University Press, 2005) (ការគូសបញ្ជាក់បន្ថែម)។

[១២] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៣៥ ថ្មី។ កិច្ចព្រមព្រៀង មាត្រា ១៣(១)។ សូមមើលផងដែរ កតិកាសញ្ញាអន្តរជាតិ មាត្រា ១៤(៣)(ង)។ U.N. CCPR មតិយោបល់ទូទៅលេខ ៣២ មាត្រា ១៤៖ សិទ្ធិមានភាពស្មើគ្នាចំពោះមុខតុលាការ និងសាលាជម្រះក្តី កថាខណ្ឌ ៣៣ U.N. Doc. CCPR/C/GC/32 ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៧ មានដាក់ផ្សាយជូននៅលើ http://daccess-dds-ny.un.org/doc/UNDOC/GEN/G07/437/71/PDF/G0743771.pdf?OpenElement ("មតិយោបល់ទូទៅលេខ ៣២")។

ទាំងឡាយរបស់អយ្យការ"[១៣]។ សិទ្ធិទទួលបានសម្ភារៈគ្រប់គ្រាន់ រួមមាន "លទ្ធភាពពិនិត្យមើលឯកសារ និងភស្តុតាងផ្សេងៗ"[១៤] រួមទាំងសម្ភារៈដោះបន្ទុក[១៥] និងលទ្ធភាពពិនិត្យមើលខ្លឹមសារសំខាន់ៗនៃឯកសារទាំងអស់ ដែលអាចយកមកប្រើប្រាស់ជាភស្តុតាងនៅក្នុងពេលជំនុំជម្រះក្តី[១៦]។ "សម្ភារៈដោះបន្ទុក" រួមមានទាំងសម្ភារៈបង្ហាញនិរទោស និង "ភស្តុតាងផ្សេងទៀតដែលអាចជួយជ្រោមជ្រែងដល់ការការពារក្តី"[១៧]។ វាបង្ហាញឲ្យយើងឃើញយ៉ាងច្បាស់ថា គោលការណ៍ទាំងនេះអនុវត្តនៅក្នុងបរិបទច្បាប់ស៊ីវិលឡ ដែលជនជាប់ចោទ ទទួលបាន "សិទ្ធិពិនិត្យសំណុំឯកសារស៊ើបអង្កេតទាំងមូល ដោយគ្មានកំហិត" មុនពេលសំណុំរឿងឈានដល់ការជំនុំជម្រះ"[១៨] ព្រមទាំង

---

[១៣] រឿងក្តី *Ismailov* ទល់នឹង *Uzbekistan,* CCPR/C/101/D/1769/2008, Communication No. 1769/2008 ចុះថ្ងៃទី ២៨ ខែ មេសាឆ្នាំ ២០១១ កថាខណ្ឌ ៧.៥។ រឿងក្តី *Peart & Peart* ទល់នឹង *Jamaica*, CCPR/C/54/D/464/1991 & 482/1991, Communication Nos. 464/1991 & 482/1991 ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៥ កថាខណ្ឌ ១១.៥៖ "គណៈកម្មាធិការពិចារណាឃើញថា ការខកខានមិនបានផ្តល់របាយការណ៍របស់នគរបាលអំពីសាក្សីជូនក្រុមមេធាវីការពារក្តី គឺជាការរារាំងយ៉ាងធ្ងន់ធ្ងរដល់ក្រុមមេធាវីការពារក្តី នៅក្នុងការដេញដោលលើសាក្សីរូបនេះ ដែលជាហេតុដកហូតនូវសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ក្រុមមេធាវីការពារក្តី"។ សូមមើលផងដែរ រឿងក្តី *Windisch* ទល់នឹង *Austria* តុលាការសិទ្ធិមនុស្សអឺរ៉ុប No. 12489/86 ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ១៩៩០ កថាខណ្ឌ ២៨៖ "ការដែលមិនបានដឹងអំពីអត្តសញ្ញាណរបស់សាក្សីអនាមិកចំនួន ២ រូប គឺបានធ្វើឲ្យក្រុមមេធាវីការពារក្តី ស្ទើរតែប្រឈមនឹងឧបសគ្គរារាំងមិនអាចដោះស្រាយបាន ពោលគឺ វាជាការដកហូតនូវព័ត៌មានចាំបាច់ ដែលអនុញ្ញាតឲ្យក្រុមមេធាវីការពារក្តី ដេញដោលលើភាពទុកចិត្តលើសាក្សី ឬ បង្កើតជាចំណុចសង្ស័យលើការជឿជាក់លើសាក្សី"។ (សេចក្តីដកស្រង់ពីផ្នែកខាងក្នុង ត្រូវបានលុបចោល)។

[១៤] មតិយោបល់ទូទៅលេខ ៣២ កថាខណ្ឌ ៣៣។

[១៥] ដូចខាងលើ។

[១៦] STEFAN TRECHSEL, HUMAN RIGHTS IN CRIMINAL PROCEEDINGS 229 (Oxford 2005): "ព័ត៌មានណា ដែលក្រុមមេធាវីការពារក្តីមិនបានដឹងពីមុនមក អាចត្រូវបានយកមកប្រើប្រាស់សម្រាប់ធ្វើតែជាភស្តុតាង ប្រសិនបើក្រុមមេធាវីការពារក្តីមានឱកាស យ៉ាងហោចណាស់ ដឹងត្រួសៗអំពីខ្លឹមសារសំខាន់ៗរបស់វានោះ"។

[១៧] មតិយោបល់ទូទៅលេខ ៣២ កថាខណ្ឌ ៣៣។

[១៨] Mirjan R. Damaška, *Evidentiary Barriers to Conviction and Two Models of Criminal Procedure: A Comparative Study*, 121 U. PA. L. REV. 506, 533, 559 (1972-73) ("Damaška")។ សូមមើលផងដែរ វិធាន ៨៦ នៃវិធានផ្ទៃក្នុង៖ "ទោះក្នុងករណីណាក៏ដោយ សហព្រះរាជអាជ្ញា និងមេធាវីតំណាងឲ្យភាគី ត្រូវមានសិទ្ធិពិនិត្យ និងទទួលឯកសារសំណុំរឿង ក្រោមការត្រួតពិនិត្យរបស់ក្រឡាបញ្ជីនៃអង្គជំនុំជម្រះ ក្នុងអំឡុងពេលនៃថ្ងៃធ្វើការ និងដោយគោរពទៅតាមលក្ខខណ្ឌស្តីពីការប្រព្រឹត្តទៅឲ្យបានសមស្របរបស់ អ.វ.ត.ក។ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ៤៨ មាត្រា ១២៩ មាត្រា ១៤៥ មាត្រា ២៥៩ មាត្រា ៣០៤ មាត្រា ៣១៩។ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង មាត្រា ១១៤ ដែលមេធាវីការពារក្តីមានសិទ្ធិពិនិត្យគ្រប់ឯកសារសម្ងាត់ទាំងអស់ ក៏ប៉ុន្តែ ត្រូវគោរពការសម្ងាត់នៃការស៊ើបអង្កេតព្រហ្មទណ្ឌ។ មេធាវីអាចថតចម្លងឯកសារឲ្យជនជាប់

"បង្ហាញយ៉ាងច្បាស់" ថា "ការដឹងសំណុំឯកសារជាមុន គឺជាលក្ខខណ្ឌដ៏មានសារៈសំខាន់សម្រាប់ការការពារក្ដី"[១៩]។

៦. សិទ្ធិរបស់លោក អៀង សារី ក្នុងការពិនិត្យភស្តុតាង និងសាក្សី ដាក់បន្ទុកមកលើខ្លួន និងសិទ្ធិទទួលបានសម្ភារៈគ្រប់គ្រាន់ ដើម្បីការពារខ្លួន ត្រូវបានរំលោភ ប្រសិនបើមិនអនុញ្ញាតឲ្យលោកមានលទ្ធភាពពិនិត្យមើលគ្រប់ឯកសារទាំងអស់ នៅក្នុងសំណុំរឿងទេនោះ។ នៅក្នុងពេលបច្ចុប្បន្ន ក្រុមមេធាវីការពារក្ដី មិនមានលទ្ធភាពពិនិត្យមើលឯកសារប្រមាណជាង ៥០០០ ឯកសារ នៅក្នុងសំណុំរឿង។ ចំនួនឯកសារទាំងនេះ យ៉ាងហោចណាស់ ស្មើនឹង ៧% នៃឯកសារនៅក្នុងសំណុំរឿងទាំងមូល[២០]។ ប្រសិនបើមិនមានលទ្ធភាពពិនិត្យមើលឯកសារទាំងនេះទេនោះ ក្រុមមេធាវីការពារក្ដី នឹងមិនដឹង ថាតើខ្លួនត្រូវចាំបាច់ ឬ ពុំចាំបាច់បដិសេធលើការទទួលយកឯកសារទាំងនេះ នឹងមិនដឹង ថាតើឯកសារទាំងនេះរួមមាន ឬក៏ពុំមានសម្ភារៈដោះបន្ទុក ឬ មិនដឹងថាតើឯកសារទាំងនេះ ចាំបាច់ ឬ ពុំចាំបាច់សម្រាប់បង្ហាញបរិបទពាក់ព័ន្ធនោះទេ។ ហេតុដូច្នេះ ក្រុមមេធាវីការពារក្ដីទាមទារលទ្ធភាពពិនិត្យមើលគ្រប់ឯកសារសម្ងាត់បំផុតទាំងអស់នៅក្នុងសំណុំរឿង។

### ២. គោលការណ៍សមភាពរវាងគូភាគីក្ដី បានត្រូវរំលោភ នៅពេលលោក អៀង សារី មិនទទួលបានការអនុញ្ញាតឲ្យពិនិត្យមើលឯកសារសម្ងាត់បំផុត ដែល ក.ស.ព យកមកសំអាង

---

ចោទ លើកលែងតែចៅក្រមស៊ើបសួរពិចារណាឃើញថា ការលាតត្រដាងព័ត៌មាននោះនឹងបង្កើតជាហានិភ័យ ដែលនាំឲ្យមានការដាក់សម្ពាធលើជនរងគ្រោះ ជនដែលកំពុងស្ថិតនៅក្រោមការត្រួតពិនិត្យ ឬ មេធាវីរបស់ពួកគេ សាក្សី មន្ត្រីស៊ើបអង្កេត អ្នកជំនាញ ឬ ជនដទៃទៀតដែលជាប់ពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ។ នៅក្នុងកាលៈទេសៈទាំងនោះ លទ្ធភាពរបស់ក្រុមមេធាវីការពារក្ដី ក្នុងការពិនិត្យឯកសារសម្ងាត់ អាចត្រូវបានបដិសេធចោល ដរាបណាចៅក្រមស៊ើបសួរផ្ដល់ហេតុផលជាក់លាក់ចំពោះការបដិសេធនោះ ក្នុងរយៈពេល ៥ ថ្ងៃ នៃថ្ងៃធ្វើការ។ ការបដិសេធនេះ បើកផ្លូវឲ្យប្ដឹងឧទ្ធរណ៍ ទៅប្រធានសភាស៊ើបសួរ។ សូមមើលផងដែរ Caroline Buisman និងជនដទៃទៀត, *Principles of Civil Law*, in KARIM A. A. KHAN, CAROLINE BUISMAN & CHRISTOPHER GOSNELL EDS., PRINCIPLES OF EVIDENCE IN INTERNATIONAL CRIMINAL JUSTICE 23 (Oxford 2010)៖ "មេធាវីការពារក្ដីមានសិទ្ធិពិនិត្យមើលសំណុំឯកសារទាំងមូល ដើម្បីរកភាពមិនពេញលេញ។ មេធាវីការពារក្ដីអាចធ្វើដូច្នេះបាននៅចំពោះមុខ...តុលាការ។ បើមិនដូច្នេះ ឬ លើសពីនេះនោះ មេធាវីការពារក្ដី អាចស្នើសុំឲ្យបំពេញបន្ថែមនូវឯកសារ ដែលនៅខ្វះនេះ ទៅក្នុងសំណុំឯកសារ ដែល ជាគោលការណ៍ ករណីនេះមិនត្រូវបានគេបដិសេធឡើយ។ ព័ត៌មានទាំងឡាយ អាចដកហូតពីចុងចោទបាន ក្នុងករណីដែលផលប្រយោជន៍ជាក់លាក់នៃការស៊ើបអង្កេត តម្រូវ"។

[១៩] STEFAN TRECHSEL, HUMAN RIGHTS IN CRIMINAL PROCEEDINGS 224 (Oxford 2005)។

[២០] បញ្ជីសារពើភណ្ឌសំណុំរឿង ចុះថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ២០១១ បង្ហាញនូវឯកសារចំនួន ៧២៩២១ ឯកសារ នៅក្នុងសំណុំរឿង។

៧. លោក អៀង សារី មានសិទ្ធិទទួលបានសមភាពតទល់ជាមួយនឹងគូភាគី ក.ស.ព។ គណៈកម្មាធិការសិទ្ធិមនុស្សបានសម្រេចរួចមកហើយ វាជា "កាតព្វកិច្ចរបស់តុលាការ...ក្នុងការធ្វើយ៉ាងណាឲ្យភាគីនីមួយៗ [អាច] តវ៉ាលើឯកសារភស្តុតាង ដែល [ភាគី] ម្ខាងទៀត បានដាក់មក ឬ មានបំណងដាក់មក ព្រមទាំងមានបំណងចង់លើកកិច្ចដំណើរការនីតិវិធី ទៅពេលក្រោយ នៅក្នុងករណីចាំបាច់"[២១]។ ដូចគ្នានេះដែរ តុលាការបានសម្រេចថា គោលការណ៍សមភាពនៃការតទល់ក្ដីរវាងគូភាគីក្ដី រួមមាន "លទ្ធភាពនៅក្នុងការជំទាស់តវ៉ាលើគ្រប់ទឡ្ហីករណ៍ និងភស្តុតាងទាំងអស់ដែលដាក់ជូនដោយភាគីម្ខាងទៀត"[២២]។

៨. ប្រសិនបើមិនមានលទ្ធភាពពិនិត្យមើលឯកសារសម្ងាត់បំផុតនៅក្នុងសំណុំរឿងទេនោះ សិទ្ធិរបស់លោក អៀង សារី ក្នុងការទទួលបានសមភាពតទល់ជាមួយនឹងគូភាគី ក.ស.ព នឹងត្រូវបានរំលោភ។ ក.ស.ព បានយកឯកសារសម្ងាត់បំផុតមកសំអាង នៅក្នុងបញ្ជីឈ្មោះសាក្សី និងបញ្ជីឯកសាររបស់ខ្លួន[២៣]។ វានឹងមិនមានសមភាពតទល់រវាងគូភាគីក្ដីឡើយ ប្រសិនបើក្រុមមេធាវីការពារក្ដី មិនមានលទ្ធភាពពិនិត្យមើលឯកសារនានា ដែល ក.ស.ព យកមកសំអាង ដើម្បីឲ្យខ្លួនអាចបំពេញភារកិច្ចដោះបន្ទុក ដែលអាចឲ្យតុលាការជឿជាក់បាន។ ក្រុមមេធាវីការពារក្ដី ទាមទារលទ្ធភាពពិនិត្យមើលគ្រប់ឯកសារសម្ងាត់បំផុតទាំងអស់នៅក្នុងសំណុំរឿង។

### ខ. ការបង្ហាញត្រឹមតែចំណងជើងទូទៅនៃឯកសារសម្ងាត់បំផុត មិនគ្រប់គ្រាន់ក្នុងការប៉ះប៉ូវចំពោះការប៉ះពាល់លើសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌របស់លោក អៀង សារី នោះទេ

៩. ក្រុមមេធាវីការពារក្ដី អាចមានលទ្ធភាពពិនិត្យមើលបញ្ជីសារពើភណ្ឌសំណុំរឿង ដែលត្រឹមតែបង្ហាញចំណងជើងទូទៅនៃឯកសារសម្ងាត់បំផុតតែប៉ុណ្ណោះ។ ការបង្ហាញនេះ បានធ្វើឡើងដោយអនុលោមតាមមាត្រា ១០.១ នៃសេចក្ដីណែនាំអនុវត្ត ដែលចែងថា៖

---

[២១] រឿងក្ដី *Jansen-Gielen* ទល់នឹង *The Netherlands*, CCPR/C/71/D/846/1999, Communication No. 846/1999 ចុះថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០០១ កថាខណ្ឌ ៨.២។

[២២] រឿងក្ដី *Äärelä* និង *Näkkäläjärvi* ទល់នឹង *Finland*, CCPR/C/73/D/779/199, Communication No. 779/1997 ចុះថ្ងៃទី ៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ កថាខណ្ឌ ៧.៤។

[២៣] ដូចខាងលើ កថាខណ្ឌ ២។

បញ្ជីសារពើភណ្ឌសំណុំរឿងផ្នែកសម្ងាត់បំផុតត្រូវមានចំណងជើងថា ឯកសារសាធារណៈ និង សម្ងាត់។ បញ្ជីសារពើភណ្ឌនេះក៏មានចំណងជើងនៃឯកសារសម្ងាត់បំផុតដែរ ដើម្បីឱ្យបុគ្គលម្នាក់ៗ អាចពិនិត្យមើលតែចំណងជើង ដើម្បីដឹងប្រភេទនៃឯកសារ ដោយមិនចាំបាច់ដឹងអំពីខ្លឹមសារទាំងស្រុងនៃឯកសារសម្ងាត់បំផុតនេះទេ។

ការបង្ហាញដូច្នេះ មិនគ្រប់គ្រាន់ក្នុងការប៉ះប៉ូវចំពោះការប៉ះពាល់ដល់សិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ លោក អៀង សារី ដូចបានពិភាក្សានៅក្នុងចំណុចខាងលើឡើយ។

១០. តុលាការសិទ្ធិមនុស្សអឺរ៉ុប បានសម្រេចថា "មានតែវិធានការទាំងឡាយណា ដែលកម្រិតសិទ្ធិរបស់ក្រុមមេធាវីការការពារក្តី ដែលចាំបាច់យ៉ាងខ្លាំង តែប៉ុណ្ណោះ ដែលអាចធ្វើទៅបាន...។ [ដើម្បី] ធានាថា ជនជាប់ចោទទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ការពិបាកណាមួយ ដែលកើតមានចំពោះក្រុមមេធាវីការពារក្តី តាមរយៈការដាក់កំហិតលើសិទ្ធិរបស់គេនោះ ត្រូវតែប៉ះប៉ូវឱ្យបានគ្រប់គ្រាន់ ដោយនីតិវិធី ដែលអាជ្ញាធរតុលាការបានអនុវត្ត..."[២៤]។ ការបដិសេធមិនឱ្យក្រុមមេធាវីការពារក្តី មានលទ្ធភាពពិនិត្យមើលគ្រប់ឯកសារអ្វីទាំងអស់ ក្រៅតែការពិពណ៌នាទូទៅអំពីឯកសារសម្ងាត់បំផុតជាង ៥០០០ ឯកសារ មិនមែនជា "លក្ខខណ្ឌចាំបាច់បំផុតនោះទេ"។ ដោយពិចារណាឃើញថា ឯកសារសម្ងាត់បំផុត ត្រូវបានដកស្រង់យកមកដាក់នៅក្នុងបញ្ជីឈ្មោះសាក្សី និងបញ្ជីឯកសាររបស់ ក.ស.ព ព្រមទាំងក្រោយពីពិនិត្យឃើញមានឯកសារទាំងនេះច្រើននៅក្នុងសំណុំរឿង ការបដិសេធក្រុមមេធាវីការពារក្តី មិនឱ្យមានលទ្ធភាពពិនិត្យមើលភស្តុតាងដ៏មានសក្តានុពល មិនអាចចាត់ទុកថាជា "លក្ខខណ្ឌចាំបាច់បំផុតនោះទេ"។

១១. ព័ត៌មានទូទៅ ដូចបានលើកឡើងនៅក្នុងបញ្ជីសារពើភណ្ឌសំណុំរឿង មិនបានបញ្ជាក់ឱ្យបានសមរម្យ អំពីលក្ខណៈនៃឯកសារសម្ងាត់បំផុត ដែលឯកសារទាំងនេះបានរៀបរាប់ (ដែលជាលក្ខខណ្ឌមានចែងនៅក្នុងមាត្រា ១០.១ នៃសេចក្តីណែនាំអនុវត្ត)។ ព័ត៌មានទាំងនេះគ្រាន់តែបញ្ជាក់

[២៤] រឿងក្តី *Rowe និង Davis ទល់នឹង United Kingdom*, Eur.Ct.H.R. No. 28901/95 ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០០ កថាខណ្ឌ ៦១។ *សូមមើលផងដែរ Van Mechelen និងជនដទៃទៀត ទល់នឹង Netherlands*, Eur.Ct.H.R. Nos. 21363/93, 21364/93, 21427/93, 22056/93 ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ១៩៩៧ កថាខណ្ឌ ៥៨៖ "ដោយពិនិត្យមើលទីកន្លែងដែលមានការគោរពលើសិទ្ធិទទួលបានការរកយុត្តិធម៌ដោយត្រឹមត្រូវ នៅក្នុងសង្គមប្រជាធិបតេយ្យ វិធានការណាមួយដែលកម្រិតសិទ្ធិរបស់មេធាវីការពារក្តី គួរត្រូវប្រកាន់យកឱ្យបានតឹងរ៉ឹង។ ប្រសិនបើវិធានការណាមួយដែលមានលក្ខណៈមិនសូវកំហិតជាងនេះ អាចមានលក្ខណៈសមល្មម វិធានការនេះគួរយកមកអនុវត្ត"។

ថា ឧទាហរណ៍ ឯកសារនេះ ជា "ពាក្យសុំរបស់ជនរងគ្រោះ" "របាយការណ៍" ឬ "លិខិត" តែប៉ុណ្ណោះ[២៥]។ ការប៉ះពាល់ដល់សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់លោក អៀង សារី ដោយបដិសេធមិនឱ្យលោកមានលទ្ធភាពពិនិត្យមើលឯកសារសម្ងាត់បំផុតនោះ មិនអាចប៉ះប៉ូវតាមរយៈការលាតត្រដាងតែចំណងជើងទូទៅទាំងនេះឡើយ។

**គ. ក្នុងករណីដែលអង្គជំនុំជម្រះសាលាដំបូងរកឃើញថា ក្រុមមេធាវីការពារក្តីមិនមានលទ្ធភាពដោយស្វ័យប្រវត្តិក្នុងការពិនិត្យគ្រប់ឯកសារសម្ងាត់បំផុតទាំងអស់នៅក្នុងសំណុំរឿងទេនោះ ក្រុមមេធាវីការពារក្តីសូមស្នើឱ្យអង្គជំនុំជម្រះពិនិត្យឯកសារទាំងនេះ *ជាអសាធារណៈ* ឡើងវិញ**

១២. អង្គជំនុំជម្រះសាលាដំបូង មានយុត្តាធិការធ្វើចំណាត់ថ្នាក់ឯកសារសម្ងាត់បំផុតទាំងនេះឡើងវិញទៅតាមកម្រិតនៃការសម្ងាត់ ហើយមានយុត្តាធិការផ្តល់លទ្ធភាពឱ្យភាគីអាចពិនិត្យមើលឯកសារទាំងនេះបាន[២៦]។ កើតចេញពីចំណុចនេះហើយដែល អង្គជំនុំជម្រះសាលាដំបូងនឹងមានយុត្តាធិការពិនិត្យឯកសារសម្ងាត់បំផុតទាំងអស់នេះ *ជាអសាធារណៈ* ឡើងវិញ។ ក្នុងករណីដែលអង្គជំនុំជម្រះសាលាដំបូងរកឃើញថា ក្រុមមេធាវីការពារក្តីមិនគួរមានលទ្ធភាពដោយស្វ័យប្រវត្តិក្នុងការពិនិត្យគ្រប់ឯកសារសម្ងាត់បំផុតទាំងអស់នៅក្នុងសំណុំរឿងទេនោះ ក្រុមមេធាវីការពារក្តីសូមស្នើឱ្យអង្គជំនុំជម្រះពិនិត្យគ្រប់ឯកសារបែបនេះទាំងអស់ *ជាអសាធារណៈ* ឡើងវិញ ដើម្បីកំណត់ថាតើឯកសារទាំងនេះ ប្រសិនបើមាន គួរលាតត្រដាងឱ្យក្រុមមេធាវីការពារក្តីបានដឹងដែរឬទេ ដោយមិនគិត ថាតើឯកសារទាំងនោះ ទំនងជាអាច ឬក៏ពុំអាចយកមកបង្ហាញនៅក្នុងការជំនុំជម្រះក្តីឡើយ។ ការពិនិត្យឡើងវិញ*ជាអសាធារណៈ* លើគ្រប់ឯកសារសម្ងាត់បំផុតទាំងអស់នោះ អាចការពារសិទ្ធិនៅក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់លោក អៀង សារី ហើយក៏អាចការពារការសម្ងាត់នៃឯកសារផងដែរ[២៧]។

---

[២៥] *សូមមើល* ឧបសម្ព័ន្ធ។

[២៦] សេចក្តីណែនាំអនុវត្ត មាត្រា ២(ឃ)(iii) មាត្រា ៩.១។

[២៧] រឿងក្តី *Pennsylvania ទល់នឹង Ritchie*, 480 U.S. 39, 60-61 (1987)៖ "យើងយល់ឃើញថា សិទ្ធិរបស់[ជនជាប់ចោទ] ក៏ដូចជា សិទ្ធិរបស់ [អយ្យការ] នៅក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ អាចត្រូវបានការពារបានពេញលេញ ដរាបណាឯកសារ [សម្ងាត់] ត្រូវដាក់ជូនតែចំពោះតុលាការជំនុំជម្រះតែមួយគត់ ដើម្បីឱ្យតុលាការនេះពិនិត្យមើលឡើងវិញ *ជាអសាធារណៈ* បាន។...ការពិនិត្យមើលឡើងវិញ*ជាអសាធារណៈ* ដោយតុលាការជំនុំជម្រះ នឹងបម្រើដល់ផលប្រយោជន៍របស់

១៣. ការពិនិត្យមើលឯកសារ *ជាអសាធារណៈ* ឡើងវិញ មានភាពសមរម្យនៅក្នុងដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនេះ។ អង្គជំនុំជម្រះសាលាដំបូង មានលទ្ធភាពសមរម្យក្នុងការវាយតម្លៃ ថាតើសម្ភារៈណាខ្លះ អាចពាក់ព័ន្ធនឹងក្រុមមេធាវីការពារក្តី ហើយគួរតែធ្វើការលាតត្រដាងឲ្យខ្លួនបានដឹង។ អង្គជំនុំជម្រះសាលាដំបូង ក៏អាចកំណត់ ថាតើឯកសារណាខ្លះ គួររក្សាទុកថាជាឯកសារសម្ងាត់បំផុតដដែល និងមិនគួរលាតត្រដាងដល់ភាគីផ្សេងៗបានដឹង។ មេធាវីការពារក្តី ជំទាស់ទៅនឹងភាពអាចទទួលយកបាននៃភស្តុតាងរបស់ឯកសារនានា និងជំទាស់ទៅនឹងការសំអាងទៅលើឯកសារនានា ដែលឯកសារទាំងនោះមិនបានលាតត្រដាងបង្ហាញដល់មេធាវីការពារក្តី។

**អាស្រ័យហេតុនេះ** យោងទៅលើសំអាងហេតុទាំងអស់ដូចបានលើកឡើងនៅក្នុងសំណើសុំនេះ ក្រុមមេធាវីការពារក្តី សូមស្នើដោយគោរពឲ្យអង្គជំនុំជម្រះសាលាដំបូង **ផ្តល់**លទ្ធភាពឲ្យក្រុមមេធាវីការពារក្តីបានពិនិត្យមើលគ្រប់ឯកសារសម្ងាត់បំផុតទាំងអស់ ឬក៏ជាជម្រើសម្យ៉ាងទៀត **ពិនិត្យ** *ជាអសាធារណៈ* លើគ្រប់ឯកសារសម្ងាត់បំផុតនៅក្នុងសំណុំរឿង ដើម្បីកំណត់ ថាតើឯកសារណាខ្លះ ប្រសិនបើមាន គួរលាតត្រដាងឲ្យក្រុមមេធាវីការពារក្តីបានដឹង; និង **បដិសេធ**មិនទទួលយកជាភស្តុតាង ឬ សំអាងទៅលើឯកសារ "សម្ងាត់បំផុត" ដែលមិនបានបង្ហាញដល់មេធាវីការពារក្តី។

សូមចៅក្រមអង្គជំនុំជម្រះសាលាដំបូងទទួលយកសារណានេះដោយក្តីគោរព។

---

[ជនជាប់ចោទ] ដោយគ្មានការបំផ្លាញនូវភាពចាំបាច់របស់ [អយ្យការ] នៅក្នុងការការពារការសម្ងាត់របស់អ្នកដែលពាក់ព័ន្ធនៅក្នុងការស៊ើបអង្កេតលើការរំលោភបំពានលើអនីតិជន"។ ម្យ៉ាងវិញទៀត កាតព្វកិច្ចរបស់តុលាការជំនុំជម្រះ ក្នុងការលាតត្រដាងព័ត៌មាននោះ គឺជាកាតព្វកិច្ចត្រូវធ្វើជាដរាប។ "ព័ត៌មានដែលអាចចាត់ទុកថាមិនពាក់ព័ន្ធនឹងការពិនិត្យពីដំបូង អាចប្រែជាមានសារៈសំខាន់ នៅពេលកិច្ចដំណើរការនីតិវិធីវិវឌ្ឍទៅមុខ ហើយតុលាការអាចមានកាតព្វកិច្ចបញ្ចេញនូវព័ត៌មានទាំងនេះ ដែលពាក់ព័ន្ធនឹងភាពយុត្តិធម៌នៃការជំនុំជម្រះ"។ *ដូចខាងលើ* ត្រង់ ៦០។ សូមមើលផងដែរ 23 Am Jur 2d Depositions and Discovery § 282៖ "អយ្យការត្រូវអនុញ្ញាឲ្យជនជាប់ចោទពិនិត្យមើល និងថតចម្លងភស្តុតាងដោះបន្ទុក ដែលដកស្រង់ចេញពីសំណុំឯកសារ។ ប្រសិនបើរដ្ឋាភិបាលមានមន្ទិលសង្ស័យអំពីការរកឃើញនូវភស្តុតាង ដែលមិនបានស្នើសុំនោះ រដ្ឋាភិបាលគួរបញ្ជូនឯកសារនេះទៅកាន់តុលាការដើម្បីពិនិត្យឡើងវិញ *ជាអសាធារណៈ*"។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **១៤** ខែ **កញ្ញា** ឆ្នាំ **២០១១**
សហមេធាវីការពារក្តីរបស់លោក អៀង សារី

____________________ __________________________

**អាង ឧត្តម** **Michael G. KARNAVAS**